# រឿងតក្កបណ្ឌិត

(ទោសកាមេសុមិច្ឆាចារ)

កាល ពីអតីតកាល ព្រះបរមពោធិសត្វរបស់យើងជាតាបសនៅជាសុខក្នុងឈាន នាបណ្ណសាលាទៀប ឆ្នេរគង្គារ ។ មានសេដ្ឋីធីតានៅក្នុងក្រុងពារាណសីម្នាក់ ឈ្មោះទុដ្ឋកុមារី ជាស្ត្រីកាចឆ្នាស់ឃោរឃៅ បានជេរប្រទេចវាយពួកកម្មករទាំងឡាយមិនសំចៃដៃឡើយ ។

ថ្ងៃមួយពួកកម្មករទាំងនោះបានចាប់យកនាងទៅទំលាក់ក្នុងស្ទឹងគង្គា ។ ទុដ្ឋកុមារី នោះអណ្តែតទៅតាមខ្សែទឹកស្រែកយំហ៊ៗ ដល់ទៅកន្លែងក្បែរសាលាបរមពោធិសត្វតាបស ក្នុងពេលអាធ្រាតសន្លប់បាត់ស្មារតី ។តាបសក៏ស្រង់នាងពីទឹក ដោយសេចក្តីសង្គ្រោះហើយឆ្អើរដរាបដល់នាង មានស្មារតីឡើង ទើបឲ្យផ្លែឈើទុំខ្ទីបរិភោគហើយសួរថា នាងនៅក្នុងទីណា ? ចាពារាណសីក្រុងក្នុងនៅ ! ) ទៅឥឡូវទៅចូរតា ។ នាងលោក តាបសពោលយ៉ាងនេះ ដោយខ្លាចនាងធ្វើទុក្ខបុកម្នេញ ម៉្ងិកម្ងក់ឲ្យធ្លុះធ្លាយសីលរបស់ខ្លួន។ (

ស្រីនោះគិតថាអញត្រូវប្រលោមតាបសនេះ ដោយធ្វើអាការៈញ៉េះញោះលុះត្រាតែមានតម្រេកស្នេហ៍សិទ្ធទប់មិនបាន ដោយកាមតណ្ហាបានជាគូសង្សារសិនសិមទៅទាំងពីរនាក់ ។ តាបសទប់អាត្មាមិននឹង ដោយមេអសុភស្រស់លងបន្លាចបង្ហាញអាការគួរស្ញើបក្រៃពេក ក៏រលំខ្លួនទៅផ្តេកផ្តិតសិទ្ធស្នាលស្នេហាលុះត្រាតែធ្លុះធ្លាយ សីលសាបសូន្យ ក៏ទៅកាន់ស្រុកប្រទល់ដែនជាមួយស្រីនោះ ហើយលក់ដូរខ្លាញ់បានប្រាក់បន្តិចបន្តួចគ្រាន់នឹងទិញស្បៀងអាហារ ចិញ្ចឹមគូសង្សាររបស់ខ្លួនរាល់ថ្ងៃ ។

ព្រោះហេតុនោះ ជនទាំងឡាយក៏កំណត់នាមធេយ្យតាបសតាមហេតុនោះថា តក្កបណ្ឌិត ។ មនុស្សទាំងឡាយក៏ឲ្យបរិព្វយវត្ថុដល់តក្កបណ្ឌិតនោះ ហើយឲ្យកូនខ្ទមមួយគ្រាន់ជាទីជ្រកកោនទៀបទ្វារស្រុក ។

ថ្ងៃមួយ ពួកចោរចូលទៅប្លន់ស្រុកនោះ ហើយចាប់យកប្រពន្ធតក្កបណ្ឌិតទៅឲ្យមេរបស់ខ្លួន ។ មេចោរក៏ទទួលយកស្រីនោះធ្វើជាស្រីកំណាន់ ។ នាងនោះចង់សម្លាប់តក្កបណ្ឌិតណាស់ ក៏ធ្វើជាលិខិតមួយផ្ញើទៅប្រាប់ថា បពិត្រ ស្វាមីប្តីកំសត់

ឥឡូវនេះខ្លួនប្អូនមានទុក្ខជាខ្លាំង ដោយចោរទាំងឡាយចាប់យកជាស្រីកំណាន់របស់វា ប្រព្រឹត្តធ្វើកាមេសុមិច្ឆាចារ ហេតុនេះសូមយកប្អូនទៅវិញឆាប់កុំខាន ។

តក្កបណ្ឌិតក៏ទៅយ៉ាងរហ័ស ឯនាងនោះឃើញតក្កបណ្ឌិតមកដល់ខ្សឹបប្រាប់ថា ប្រសិនបើយើងទៅឥឡូវនេះ សមចោរតាមចាប់ហើយសម្លាប់យើងមិនខាន ចាំរាត្រីកាលសិនទៅ ហើយអង្គុយក្នុងបន្ទប់មួយ ទើបទៅប្រាប់មេចោរដែលកំពុងស្រវឹងស្រាក្នុងពេលល្ងាចថា ប្ដីខ្លួនមកនៅក្នុងបន្ទប់ឯណោះ ប្រុងប៉ុនប៉ងប្រមាណជីវិតលោក ។

ចោរស្ទុះទៅចាប់តក្កបណ្ឌិតចងផ្ដេកចុះ ហើយវាយតាមចិត្តក្ដៅ ។ តក្កបណ្ឌិតចោរវាយយ៉ាងណាក៏មិនស្រែកយំឡើយ គ្រាន់តែពោលថា ស្ត្រីទ្រុស្តមិត្តមានសេចក្ដីក្រោធផងមិនដឹងគុណផង ជាអ្នកញុះញង់ផង ។ ឯចោរកាលបើស្វាងស្រាហើយក៏ប្រារព្ធវាយទៀត ។ តក្កបណ្ឌិតក៏ពោលពាក្យនោះ ចោរគិតថាឃើ គាត់ ! ៗដដែលពាក្យពោលនេះ ប្រហែលជាមានហេតុយ៉ាងណាទេដឹង ? ក៏សួរតាបស ៗ ប្រាប់ដំណឹងទាំងអស់ហើយគិតម្ដងទៀត អើម្ល៉េះកាឡកណ្ណីអីនេះស្រី ! អញសម្លាប់ចោរមិនទុកទេ ក៏ដាស់ថាមកនាងអញនឹងសម្លាប់បុរសនោះ ហើយចេញទៅខាងក្រៅស្រុកបែរជាសម្លាប់ស្រីនោះវិញ ទើបនាំតក្កបណ្ឌិតទៅផ្ទះសួរថា ឥឡូវអ្នកនឹងនៅក្នុងទីណា? ខ្ញុំនឹងបួសនៅក្នុងព្រៃ ។ បើអ្នកបួស ខ្ញុំក៏បួសដែរ ។ តក្កបណ្ឌិតនិងមេចោរក៏បួសទាំងពីរនាក់ខំចំរើនឈាន និងអភិញ្ញាឲ្យកើត លុះស្លាប់ទៅបានកើតឯព្រហ្មលោកនាយ ។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)